00723708

E109/6

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១

ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បញ្ជីឯកសារ និង វត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | **ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រមបំរុង យូរ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / 08 / 2011
ម៉ោង (Time/Heure): 14 : 06
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះសូមដាក់បញ្ជីឯកសារ និងវត្ថុតាងរបស់គាត់ ដែលភ្ជាប់ជាមួយឯកសារនេះសម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង ។ អង្គជំនុំជម្រះសាលាដំបូង មិនទាន់បញ្ចប់បញ្ជីឈ្មោះសាក្សីសម្រាប់សវនាការនៅឡើយទេ[1]។ មេធាវីការពារក្តីក៏មិនអាចពិនិត្យមើលឯកសារក្នុងសំណុំរឿង ដែលត្រូវបានចំណាត់ថ្នាក់ជាឯកសារសម្ងាត់បំផុតបានដែរ (ឯកសារមួយចំនួនស្ថិតនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា)[2]។ នៅចុងបញ្ចប់ មេធាវីការពារក្តីមិនអាចពិនិត្យមើលឯកសារក្នុងសំណុំរឿងដែលមិនទាន់ត្រូវបានបកប្រែទៅជាភាសាអង់គ្លេសនៅឡើយ[3]។ ដូច្នេះ មេធាវីការពារក្តីសូមរក្សាសិទ្ធិបន្ថែមបញ្ជីនេះពីបញ្ជីឯកសាររបស់ខ្លួនសម្រាប់សវនាការទាំងមូល[4] និងពីប្រភពដទៃទៀតក្នុងអំឡុងដំណាក់កាលបួនដំបូងនៃសវនាការ ដើម្បីជួយអង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកការពិត ។ មេធាវីការពារក្តីទទួលស្គាល់ថាឆន្ទានុសិទ្ធិចុងក្រោយក្នុងការទទួលយកភស្តុតាង គឺស្ថិតនៅលើអង្គជំនុំជម្រះសាលាដំបូង[5]។ ទោះបីជាយ៉ាងណាក៏ដោយមេធាវីការពារក្តីមិនបានលះបង់គោលជំហរដែលខ្លួនបានបញ្ជាក់កាលពីលើកមុនស្តីពីបញ្ហានៃការទទួលយកភស្តុតាងឡើយ ហើយសូមដាក់សារណារបស់ខ្លួនទាក់ទងនឹង ប្រភេទឯកសារដូចខាងក្រោម៖

---

[1] នៅសវនាការបឋម ចៅក្រម Cartwright បានគូសបញ្ជាក់ថា៖«ប្រសិនបើភាគីមួយយល់ឃើញថាវាជាការចាំបាច់សម្រាប់អង្គជំនុំជម្រះសាលាដំបូងបញ្ចូលសាក្សីណាមួយ ឬអ្នកជំនាញណាមួយនៅក្នុងបញ្ជីសម្រាប់ធ្វើការដេញដោលក្នុងដំណាក់កាលដំបូងនៃសវនាការ។ អីចឹងឈ្មោះនោះ គឺនឹងមិនចាំបាច់លើកឡើងជាចំហនៅក្នុងសវនាការទេនៅពេលនេះ ។ ហើយឈ្មោះនេះ ភាគីទាំងអស់អាចផ្តល់ឈ្មោះនោះដល់អង្គជំនុំជម្រះសាលាដំបូងជាលាយលក្ខណ៍អក្សរត្រឹមថ្ងៃអង្គារ៍ទី៥ខែកក្កដា។ អង្គជំនុំជម្រះមិនមានបំណងចង់ឲ្យភាគីលើកឡើងនូវសំណើទាំងឡាយជាលាយលក្ខណ៍អក្សរអីទេ ប៉ុន្តែបើគាត់ចង់ធ្វើដូច្នេះមែន យើងអាចឲ្យភាគីហ្នឹងជួយនៅក្នុងការធានាថាធ្វើយ៉ាងម៉េចឈ្មោះរបស់អ្នកជំនាញសំខាន់ៗ ដែលមានភាពពាក់ព័ន្ធមិនត្រូវបានគេលុបចោល។ ដោយសារតែយើងយល់ដឹងពីភាពចាំបាច់នៅក្នុងការពន្លឿននូវដំណើការសវនាការ អង្គជំនុំជម្រះប្រហែលជាមានវិសាលភាពតិចតួចណាស់ក្នុងការបង្កើនចំនួនឈ្មោះក្នុងបញ្ជី», ប្រតិចារិតនៃសវនាការបឋមនៅថ្ងៃទី៤, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១, ទំព័រទី២

[2] ឧទាហរណ៍ ឯកសារ D269/8 និង D230/1.1.874 គឺជាឯកសារដែលចាត់ចំណាត់ថ្នាក់ជាឯកសារ "សម្ងាត់បំផុត" នៅលើបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ហើយមេធាវីការពារក្តីមិនអាចពិនិត្យមើលឯកសារនេះបានឡើយ។

[3] ឯកសារ IS1.5 និង IS12.10 គឺជាឧទាហរណ៍នៃឯកសារជាច្រើនទៀតនៅក្នុងសំណុំរឿងដែលមិនមានជាភាសារអង់គ្លេសឡើយ។

[4] បញ្ជីឯកសារបឋមរបស់លោក អៀង សារី ដែលមានក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងទាក់ទងនឹងបញ្ជីឯកសារបឋមថ្មីដែលជិតមកដល់របស់គាត់ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលសវនាការ, ថ្ងៃទី១ ខែមេសា ឆ្នាំ២០១១, ឯកសារ , E9/22។ បញ្ជីឯកសារបឋមលើកទី២ របស់ អៀង សារី , ថ្ងៃទី៨ ខែមេសា ឆ្នាំ២០០១, ឯកសារ, E9/24 ។ បញ្ជីឯកសារបឋមលើកទី៣របស់ អៀង សារី, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០១, ឯកសារ E9/25។

[5] វិធាន៨៧ នៃវិធានផ្ទៃក្នុង។

ក. ឯកសារដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam")

ឯកសារដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមិនសក្តិសមក្នុងការបង្ហាញការពិតណាមួយ ដែលឯកសារនេះចង់បង្ហាញនោះទេ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺប្រឡាក់ប្រឡូកដោយការលម្អៀងប្រឆាំងលោក អៀង សារី ព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាបានគាំទ្រការអះអាងថាមានអំពើប្រល័យពូជសាសន៍ ដូច្នេះឯកសាររបស់មជ្ឈមណ្ឌលនេះត្រូវបានគេប្រមូលដើម្បីគាំទ្រការអះអាងបែបនេះ ។ ការជំនុំជម្រះក្តីណាក៏ដោយដែលផ្អែកលើឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[6] ឬឯកសារដែលពាក់ព័ន្ធនឹងមជ្ឈមណ្ឌលនេះ សូម្បីតែផ្អែកខ្លះក៏ដោយ នឹងរំលោភសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[7]។

ខ. ភស្តុតាងដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្ម

ភស្តុតាងដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្ម គឺមិនអាចទទួលយកបានឡើយក្នុងដំណើរការនីតិវិធីផ្នែកតុលាការនៅចំពោះមុខ អវតក ទោះបីជាស្ថិតក្នុងទម្រង់ និង ក្នុងកាលៈទេសៈណាក៏ដោយព្រោះវាមិនបានបង្ហាញការពិតអ្វីក្រៅតែពីការពិត ដែលថា ភស្តុតាងបែបនេះទទួលបានតាមរយៈការធ្វើ

---

[6] *សូមមើល*ញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងនឹងការប្រើប្រាស់ឯកសារដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា, ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E59។ ពាក្យសុំរបស់ អៀង សារី ឱ្យអង្គបុរេជំនុំជម្រះទទួលយកសំណើធ្វើមោឃៈភាពភស្តុតាងទាំងអស់ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា, ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០, ឯកសារ D387។ បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ច្រានចោលពាក្យសុំរបស់ អៀង សារី ឱ្យអង្គបុរេជំនុំជម្រះទទួលយកសំណើធ្វើមោឃៈភាពរាល់កិច្ចស៊ើបសួរទាំងអស់ ដែលធ្វើឡើងដោយឬដោយមានការជួយជ្រំជ្រែងពីលោក Stephen Heder និង David Boyle និងពាក្យសុំរបស់ អៀង សារី ឱ្យអង្គបុរេជំនុំជម្រះទទួលយកសំណើធ្វើមោឃៈភាពរាល់ភស្តុតាងទាំងអស់ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្តឹងឧទ្ធរណ៍បន្ទាន់របស់ អៀង សារី ប្រឆាំងនឹងការបដិសេធរបស់ កសចស មិនព្រមផ្អាកដំណើរការនីតិវិធី, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D402/1/2។

[7] សូមមើលអញ្ញត្រកម្មបឋមរបស់ អៀង សារី ទៅកាន់អ្នកជំនាញ និងសំណើដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាសុំការអនុញ្ញាតដាក់សារណាបន្ថែមក្នុងរយៈពេល៣០ថ្ងៃ, ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E9/4/9។ អញ្ញត្រកម្មបឋមរបស់ អៀង សារី ទៅកាន់អ្នកជំនាញ និងសំណើដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីសុំការអនុញ្ញាតដាក់សារណាបន្ថែមក្នុងរយៈពេល៣០ថ្ងៃ, ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E9/4/3/1។ ការសង្កេតរួមរបស់ អៀង សារី ទៅលើសាក្សី និងអ្នកជំនាញមួយចំនួនដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា, ដើមបណ្តឹងរដ្ឋប្បវេណី និង នួន ជា បន្ទាប់ពីមានបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្នរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១, ឯកសារ E93/12។

ទារុណកម្មឡើយ ។ ភស្តុតាងបែបនេះ រួមបញ្ចូលទាំងឯកសារបន្ទាប់បន្សំដែលបានមកពីភស្តុតាងពាក់ព័ន្ធនឹងការធ្វើទារុណកម្មផងដែរ[8] ។

គ. <u>ចម្លើយ និងការសម្ភាសន៍របស់អ្នកដែលមិនអាចត្រូវបានតទល់ក្នុងអំឡុងសវនាការ</u>

ដូចដែលបានធានាដោយកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អវតក និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ លោក អៀង សារី សូមរក្សាសិទ្ធិតទល់សាក្សី និងអ្នកជំនាញប្រឆាំងរូបគាត់ ដែលចម្លើយ ការសម្ភាសន៍ និងការបោះពុម្ពផ្សាយរបស់ពួកគេត្រូវបានលើយកមកបង្ហាញ[9]។

អាស្រ័យលើមូលហេតុដែលបានគូសបញ្ជាក់ពីខាងលើ មេធាវីការពារក្តីសូមដាក់បញ្ជីឯកសារ និងវត្ថុតាងសម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង ហើយសូមរក្សាសិទ្ធិបំពេញបន្ថែមបញ្ជីនេះក្នុងអំឡុងពេលដំណាក់កាលបួនដំបូងនៃសវនាការ។

សូមលោក/លោកស្រីចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងទទួលយកបញ្ជីឯកសារ និងវត្ថុតាងនេះដោយក្តីគោរព។

---

[8] *សូមមើល*សំណើទាក់ទងនឹងការបង្ហាញ និងការពឹងផ្អែករបស់ កសចស ទៅលើភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម, ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩, ឯកសារ D130/7។ *សូមមើល* លិខិត ទាក់ទងនឹងការបង្ហាញ និងការពឹងផ្អែករបស់ កសចស ទៅលើភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩, ឯកសារ D/130/7/21។ បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងការបដិសេធដោយមានការសន្មត់ទុកជាមុនរបស់ កសចស ទៅលើសំណើរបស់ អៀង សារី ទាក់ទងនឹងការបង្ហាញ និងការពឹងផ្អែករបស់ កសចស ទៅលើភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩, ឯកសារ D130/7/3/។ការឆ្លើយតបរបស់ អៀង សារី ទៅកាន់ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធដោយមានការសន្មត់ទុកជាមុនរបស់ កសចស លើសំណើរបស់ អៀង សារី ទាក់ទងនឹង ការបង្ហាញ និងការពឹងផ្អែករបស់ កសចស ទៅលើភស្តុតាងដែលជាប់ពាក់ ព័ន្ធនឹងការធ្វើទារុណកម្ម, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D130/7/3/4 ។ ញត្តិរបស់ អៀង សារី ប្រឆាំងនឹងភស្តុតាងដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្មនៅសវនាការ, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E33។

[9] សូមមើលចម្លើយតបរបស់ អៀង សារី ទៅកាន់សារណាតាមវិធាន៩២របស់សហព្រះរាជអាជ្ញាទាក់ទងនឹង ការទទួលយកចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឱ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១, ឯកសារ E96/3។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៨ ខែ **សីហា** ឆ្នាំ **២០១១**

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**